ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល
លេខ: ០០២/៩៩ អបសស្ខ.ពក

# ប្រកាស

ស្ដីពី

ការកំណត់តួនាទី ភារកិច្ច របស់ភ្នាក់ងារ
ត្រួតពិនិត្យ សេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និង ជំនួយវេជ្ជសាស្ត្រ

## ទេសរដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា,
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨ ចុះថ្ងៃទី ៣០-១១-១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុ
- បានឃើញព្រះរាជក្រម នស រកម-០១៩៦-០៦ ចុះថ្ងៃទី ២៤-០១-៩៦ ប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសុខាភិបាល,
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ-បក ចុះថ្ងៃទី ២២-១០-៩៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល,
- បានឃើញសេចក្ដីសំរេចលេខ ៥០ សសរ ចុះថ្ងៃទី ០៥ មេសា ១៩៩១ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រីស្ដីពីការបង្កើតកន្លែងពិនិត្យ, ព្យាបាលជំងឺ.ព្យាបាលជំងឺមាត់-ធ្មេញ.ស្រោប.ដាក់ធ្មេញ.មន្ទីរសម្ភព.មន្ទីរពិសោធន៍វេជ្ជសាស្ត្រ និង មន្ទីរពហុព្យាបាលឯកជន;
- បានឃើញសេចក្ដីណែនាំលេខ ៩៩៥ស.នកព ចុះថ្ងៃទី ១៧-០៥-១៩៩៩ របស់ក្រសួងសុខាភិបាល,
- យោងតាមសភាពការណ៍ចាំបាច់និងដើម្បីទទួលអនុវត្ត

## សំរេច

**ប្រការ១:** ភ្នាក់ងារត្រួតពិនិត្យ សេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និង ជំនួយវេជ្ជសាស្ត្រ មានមុខងារសំខាន់ក្នុងការត្រួតពិនិត្យការអនុវត្តន៍បណ្ដាបទដ្ឋាន ក្បួនច្បាប់ដែលពាក់ព័ន្ធនិងសកម្មភាពសេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ សំដៅធានាគុណភាពនៃការគ្រប់គ្រងផ្នែករដ្ឋបាលនិងបច្ចេកទេស ។

**ប្រការ២:** ក្រុមភ្នាក់ងារត្រួតពិនិត្យ សេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និង ជំនួយវេជ្ជសាស្ត្រ ជាផ្នែកមួយឋិតនៅក្រោមនិភាពរបស់ក្រសួងសុខាភិបាលមានទីតាំងការកណ្ដាលនៅក្នុងនាយកដ្ឋានមន្ទីរពេទ្យ ។

**ប្រការ៣:** ភ្នាក់ងារត្រួតពិនិត្យ សេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និង ជំនួយវេជ្ជសាស្ត្រ មានភារកិច្ច:

១- ត្រួតពិនិត្យបែបបទ ស្នើសុំបើកសេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និង ជំនួយវេជ្ជសាស្ត្រ;

២- ណែនាំឱ្យអនុវត្តប្រកាស ឬលិខិតបទដ្ឋានផ្សេងៗ ដើម្បីលើកកំពស់សេវា;

៣- ចុះត្រួតពិនិត្យដំណើរការសេវាជាប្រចាំ ពិសេសនៅពេលមានបាតុភាពដែលកើតមានឡើងដោយថាហេតុ ។

**ប្រការ៤:** បែបបទក្នុងការចុះបំពេញបេសកកម្ម:

១- ភ្នាក់ងារត្រួតពិនិត្យអាចចុះបំពេញបេសកកម្មបានលុះត្រាតែមានលិខិតចាត់តាំងនិងមានកាលបរិច្ឆេទច្បាស់លាស់ពីអគ្គនាយកបច្ចេកទេសសុខាភិបាល ។

២- នៅពេលបំពេញបេសកកម្ម ភ្នាក់ងារត្រួតពិនិត្យត្រូវស្លៀកពាក់ឯកសណ្ឋាន:

-អាវសឺមីដៃវែងពណ៌សមានពាក់ឈ្មោះអ្នកចុះនៅលើហោប៉ៅខាងឆ្វេង ។

-ខោជើងវែង ឬ សំពត់បត់ពណ៌ខៀវចាស់ (ទឹកប៊ិច)

-នៅលើដៃអាវខាងឆ្វេងមានផ្លាកសញ្ញាក្រសួងសុខាភិបាល

-ក្រវ៉ាត់កលាតពណ៌ខៀវចាស់ (ទឹកប៊ិច)

៣- រាល់ការចុះបំពេញបេសកកម្ម ភ្នាក់ងារត្រួតពិនិត្យត្រូវធ្វើរបាយការណ៍ផ្ញើរមកក្រសួងសុខាភិបាលតាមរយៈនាយកដ្ឋានមន្ទីរពេទ្យ ។

**ប្រការ៥:** ភ្នាក់ងារត្រួតពិនិត្យមានសិទ្ធិអំណាចដូចខាងក្រោម:

១- ត្រួតពិនិត្យដំណើរការសេវា

២- ណែនាំការអនុវត្តន៍ប្រកាសឬលិខិតបទដ្ឋានផ្សេងៗ

៣- ស្នើបញ្ឈប់សកម្មភាពសេវា បើមានបទល្មើសព្រហ្មទណ្ឌកើតមានឡើង ។

**ប្រការ៦:** ជនណាប្រឆាំងនិងមុខងាររបស់ភ្នាក់ងារត្រួតពិនិត្យ ឬ ភ្នាក់ងារត្រួតពិនិត្យណាដែលឃុបឃិត ឬ ប្រព្រឹត្តរំលោភលើភារៈកិច្ចរបស់ខ្លួន ត្រូវផ្តន្ទាទោសតាមទោសប្បញ្ញត្តិដែលមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និង ជំនួយវេជ្ជសាស្ត្រ ។

**ប្រការ៧:** អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គាធិការដ្ឋាន នាយកដ្ឋានមន្ទីរពេទ្យ មន្ទីរសុខាភិបាលខេត្ត-ក្រុង មានភារកិច្ចអនុវត្តប្រកាសនេះតាមភារៈកិច្ចរៀងៗខ្លួន ។

**ប្រការ៨:** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ៩:** ប្រកាសនេះមានអនុភាពជាតពិយុត្តិចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ

ធ្វើនៅភ្នំពេញ ថ្ងៃទី ០៧ ខែ ៣ ឆ្នាំ២០០០

ទេសរដ្ឋមន្ត្រី និងជា រដ្ឋមន្ត្រី

វេជ្ជ.ហុង_ស៊ុនហួត

**ទំនាក់ទំនង**

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-អធិការកិច្ចនៃរាជរដ្ឋាភិបាល
-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-ក្រសួងមហាផ្ទៃ
-គ្រប់ខេត្ត-ក្រុង "ដើម្បីសហការអនុវត្ត"
-ដូចខ្លួនប្រការ៧
-ឯកសារកាលប្បវត្តិ